ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

លេខ: ៧៦៩ សភនវស

# សេចក្តីជូនដំណឹង
## ស្តីពី
### ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា សាកលវិទ្យាល័យនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត។

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃសាកលវិទ្យាល័យ ដែលមានអាសយដ្ឋានមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០១៥ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ ០១៧ ៦៧៨ ៧៩៧, ០១៧ ៩៦៨ ៨៨១) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ **នៅម៉ោង**៥:៣០**ថ្ងៃទី**២៥ **ខែ**កញ្ញា **ឆ្នាំ**២០១៥ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៨:៣០ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**បណ្ឌិត លុយ ចន្ធា**

**ចម្លងជូន ៖**
- ក្រុមប្រឹក្សាភិបាល
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ

អាស័យដ្ឋាន: មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ. ប្រអប់សំបុត្រ ៨៤២. ទូរស័ព្ទ: (៨៥៥) ២៣ ២១ ៤៧ ០៣. ទូរសារ: (៨៥៥) ២៣ ២១ ៤៩ ៥៣
Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, CAMBODIA. P.O. Box 842, Phone: (855) 23 21 47 03
Fax: (855) 23 21 49 53, E-mail: rector@rule.edu.kh, website: www.rule.edu.kh